# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Oct-2011, 15:48
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៦ ខែ តុលា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## ការជូនដំណឹងអំពីសំណើរបស់សហមេធាវីនាំមុខស្នើសុំពិចារណាឡើងវិញចំពោះការសម្រេចនៅក្នុងដីកាបំបែកនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ

---

ដាក់ដោយ៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ជេត វណ្ណលី

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូ ឧត្តរា

មេធាវី ហុង គីមសួន
មេធាវី គីម ម៉េងឃី
មេធាវី ឡោ ជុនធី
មេធាវី ម៉ុច សុវណ្ណារី
មេធាវី ស៊ិន សុវ៉ន
លោក គង់ ពិសី
លោក យ៉ុង ផានិត
មេធាវី សំ សុគង់
មេធាវី វ៉េន ពៅ
មេធាវី ទី ស្រីនណា
មេធាវី Silke STUDZINSKY
មេធាវី Emmanuel ALTIT
មេធាវី Pascal AUBOIN
មេធាវី Olivier BAHOUGNE
មេធាវី Patrick BAUDOIN
មេធាវី Evelyne BOILEAU-BRANDOMIR
មេធាវី Philippe CANONNE
មេធាវី Annie DELAHAIE
មេធាវី Laure DESFORGES
មេធាវី Ferdinand DJAMMEN NZEPA
មេធាវី Nicole DUMAS
មេធាវី Isabelle DURAND
មេធាវី Françoise GAUTRY
មេធាវី Marie GUIRAUD
មេធាវី Emmanuel JACOMY
មេធាវី Martine JACQUIN

<u>ចម្លងជូន៖</u>

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក Andrew CAYLEY

**ជនជាប់ចោទ៖**

ខៀវ សំផន
អៀង សារី
អៀង ធីរិទ្ធ
នួន ជា

**សហមេធាវីការពារក្តី៖**

មេធាវី សុន អរុណ
មេធាវី Michiel PESTMAN
មេធាវី Victor KOPPE
មេធាវី អាង ឧត្តម
មេធាវី Michael G. KARNAVAS
មេធាវី ផាត់ ពៅស៊ាង
មេធាវី Diana Ellis
មេធាវី ស សូវាន
មេធាវី Jacques VERGÈS

មេធាវី Daniel LOSQ

មេធាវី Christine MARTINEAU

មេធាវី Madhev MOHAN

មេធាវី Barnabé NEKUIE

មេធាវី Lyma NGUYEN

មេធាវី Elisabeth RABESANDRATANA

មេធាវី Julien RIVET

មេធាវី Fabienne TRUSSES NAPROUS

មេធាវី Nushin SARKARATI

មេធាវី Philippine SUTZ

# ការជូនដំណឹង

១. តាមរយៈការជូនដំណឹងនេះ សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នាពេលនេះ សូមជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងថា សំណើសុំឱ្យធ្វើការពិចារណាឡើងវិញ នូវការសម្រេចនៃ "ដីកាបំបែកនីតិវិធី ដោយអនុវត្តតាមវិធាន ៨៩ ស្ទួន២" នឹងត្រូវបានដាក់ជូន នៅពេលយ៉ាងឆាប់តាមតែអាចធ្វើទៅបាន បន្ទាប់ពីការឯកភាពជាឯកច្ឆ័ន្ទ[1]ត្រូវបានសម្រេចឡើង ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅលើបញ្ហាដ៏សំខាន់នេះ។ សហមេធាវីនាំមុខ នឹងស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងធ្វើការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិចារណាឡើង វិញទៅលើដីការបស់ខ្លួនដោយផ្អែកទៅលើមូលដ្ឋានដូចបានសង្ខេបជូនខាងក្រោមនេះ។

២. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបំបែកនីតិវិធីសំណុំរឿង នៅក្នុងសំណុំរឿង០០២ ឱ្យទៅជាចំណែកសវនាការជាច្រើនផ្សេងៗគ្នា ដែលផ្នែកនៃសវនាការ នីមួយៗនឹងត្រូវបានចេញជាសម្រេចទាក់ទងទៅនឹងពិរុទ្ធភាព ការកំណត់ចំនួនទោស ការសម្រេច ទៅលើសំណងរដ្ឋប្បវេណី និងការលើកចោលការចោទប្រកាន់ជាដើម។ សវនាករលើកដំបូងនឹង ត្រូវលើកឡើងតែចំនុចមួយចំនួនដូចខាងក្រោមៈ

ក. ចំនុចទាំង៤ ដែលបញ្ជាក់រួចហើយដោយអង្គជំនុំជម្រះសាលាដំបូង

ខ. ការជម្លាសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២

គ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលទាក់ទងទៅនឹងការធ្វើមនុស្សឃាដ ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា) ការផ្លាសទីដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ដែលឧក្រិដ្ឋកម្មទាំងអស់នេះជាប់ពាក់ព័ន្ធទៅនឹងការជម្លាសប្រជាជនដោយបង្ខំនៅដំណាក់កាលទី១ និងនៅដំណាក់កាលទី២។

៣. ដីកាបំបែកនីវិធីនេះមិនបានរាប់បញ្ចូលនូវសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ ទីកន្លែងសម្លាប់ មនុស្ស ការជម្លាសប្រជាជនដោយបង្ខំនៅដំណាក់កាលទី៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋ កម្មប្រឆាំងមនុស្សជាតិទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ការរៀបអាពាហ៍ ពិពាហ៍ដោយបង្ខំ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងសឺណែវឆ្នាំ១៩៤៩។

៤. នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ សហមេធាវីការពារក្តីឱ្យលោក អៀង សារី បានដាក់ជូននូវ "ការ

---

[1] វិធាន ១២ស្ទួនពីរ (៣) នៃវិធានផ្ទៃក្នុង។

គាំទ្រដោយមានលក្ខខណ្ឌដល់ព្រះរាជអាជ្ញា”[2] ។

៥. សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានយល់យ៉ាងច្បាស់អំពីផលប្រយោជន៍យុត្តិធម៌ និងភាពចាំបាច់ក្នុងការគ្រប់គ្រងចាត់ចែងពេលវេលា និងធនធាននៅពេលសវនាការ។ ពួកគេក៏បានយល់យ៉ាងច្បាស់ផងដែរអំពីផលប៉ះពាល់យ៉ាងធំធេងទៅលើភាគីដើមបណ្ដឹងរដ្ឋប្បវេណីដោយសារសេចក្ដីសម្រេចខាងលើនេះចំពោះការចូលរួមរបស់ពួកគាត់ និងប៉ះពាល់លើសំណង នៅដំណាក់កាលដំបូង ទាក់ទងនឹងវិធាន ២៣ស្ទួនបួន (១)(ក)។ ពួកគេត្រូវវាស់វែងនូវផលប្រយោជន៍របស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុមរួមគ្នាតែមួយ។ ការបំបែកនីតិវិធីផលប៉ះពាល់ទៅលើក្រុមរួម ហើយវាក៏បានបណ្ដាលឲ្យប៉ះពាល់ដល់បញ្ហាសំណងផងដែរ។ បញ្ហាគឺត្រូវតែច្បាស់ថា ផលប្រយោជន៍រួមត្រូវតែគោរព ដោយហេតុថា ផលប្រយោជន៍រួមនេះកើតចេញពីក្រុមផ្សេងៗគ្នា។ សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កំពុងកំណត់អំពីជំហររបស់ពួកគេ ហើយនឹងដាក់ជូនជាសារណាមួយ។

៦. ពួកគេបានសង្ខេបជាមុននូវសំណើសុំដូចមានខាងក្រោម៖

ក. សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគាំទ្រទាំងស្រុងសំណើសុំរបស់សហព្រះរាជអាជ្ញា ដែលស្នើឲ្យមានសវនាការផ្ទាល់មាត់មួយដើម្បីពិចារណាទៅលើបញ្ហាសំខាន់នេះ។

ខ. សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនឯកភាពគ្នាជាគោលការណ៍ចំពោះទស្សនៈយល់ឃើញរបស់អង្គជំនុំជម្រះនៅក្នុងកថាខណ្ឌទី៨ នៃដីកាបំបែកនីតិវិធីដែលកត់សំគាល់ថា “ ការកម្រិតវិសាលភាពនៃអង្គហេតុក្នុងការលើកយកមកជំនុំជម្រះនៅក្នុងដំណាក់កាលជំនុំជម្រះដំបូង មិនបានប៉ះពាល់លើលក្ខណៈនៃការចូលរួមរបស់ជនរងគ្រោះក្នុងពេលសវនាការនោះទេ ហើយការតាក់តែងសំណើសុំសំណងដែលនឹងត្រូវធ្វើជំនួសដោយសហមេធាវីនាំមុខ គួត្រូវធ្វើដោយពិចារណាទៅលើវិធាន២៣ស្ទួនបួន (១)(ក).៤”។

គ. សហមេធាវីនាំមុខ និងមេធាវីតំណាងដើបណ្ដឹងរដ្ឋប្បវេណីដឹងថា ការជំនុំជម្រះដំណាក់កាលដំបូងនេះគួរតែជា ការជំនុំជម្រះមួយតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ វាចាំបាច់ណាស់ដែលថា អង្គជនុំជម្រះសាលាដំបូងត្រូវផ្ដល់ឲ្យភាគីនូវរបៀបវារៈមួយដែលច្បាស់លាស់ចំពោះការជំនុំជម្រះក្រោយៗទៀតដែលអង្គជនុំជម្រះមានបំណងរៀបចំ នាពេលខាងមុខ ដើម្បីឲ្យ

[2] E124/3

ភាគីអាចពិចារណាពេញលេញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនាពេលនេះ។

ឃ. សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ជាការមិនសមហេតុផល និងមិនមានមូលដ្ឋានទេក្នុងការរកំរឹតការកំណត់លក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់នានា។ មានតែសវនាការមួយតែប៉ុណ្ណោះដែលអាចធ្វើយុត្តិកម្មចំពោះការកំរឹតបែបនេះ។ ក្នុងករណីណាក៏ដោយ ប្រសិនបើមានការបំបែកកិច្ចដំណើរការនីតិវិធីបែបនេះ វាគួរតែជាការបំបែកតែលើអង្គហេតុប៉ុណ្ណោះ។

ង. សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមសង្កត់ធ្ងន់លើភាពចាំបាច់ដើម្បីស្តាប់នូវរាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលនឹងត្រូវបានកោះហៅ និងត្រូវបានពិនិត្យសាកសួរនៅលើគ្រប់អង្គហេតុ និងព្យសនកម្មទាំងអស់ ដែលពួកគាត់បានទទួលរងនៅក្នុងការជំនុំជម្រះដំបូង ដើម្បីឲ្យមាននូវទស្សនៈរួមពេញលេញលើបទឧក្រិដ្ឋផ្សេងៗដែលបានគូសបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ។ ការជូនដំណឹងអំពីសំណើនេះ បានដាក់បន្ទាប់ពីការពិគ្រោះយោបល់លើកដំបូងជាមួយនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនឹង មានពាក្យសុំដែលនឹងត្រូវដាក់នាពេលឆាប់ៗនេះ។

សូមលោក លោកស្រីទទួលនូវក្តីគោរពអំពីយើងខ្ញុំ

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៦ ខែ តុលា ឆ្នាំ ២០១១ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |